**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (**គ.ជ.ប.ជ**)

**តាមរយៈ**៖ **-ឯកឧត្តមឧត្តមសេនីយ៍ឯក អគ្គលេខាធិការរងទទួលបន្ទុក**

**-លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីការរៀបចំទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបថា នៅថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ពុទ្ធស័ករាជពីរពាន់ប្រាំរយហុកសិបប្រាំបី ត្រូវនឹងថ្ងៃទីម្ភៃ ខែសីហា ឆ្នាំពីរពាន់ម្ភៃបួនរ វេលាម៉ោងប្រាំបី នឹងសាមសិបនាទីព្រឹក អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ក្រោមប្រធានបទ **«ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល»** ក្រោមអធិបតីភាព **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ។

គោលបំណងនៃការរៀបចំទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស គឺ៖

១.បញ្ជាក់ពីជំហរនិងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងនៅក្នុងប្រទេសកម្ពុជា កម្រិតតំបន់ និងកម្រិតអន្តរជាតិ។

២.បង្ហាញពីសុខដុមនីយកម្ម និងកិច្ចសហប្រតិបត្តិការជាផ្លូវមួយពីសំណាក់មេដឹកនាំ និងសាសនិក នៃសាសនានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងបរិបទសង្គមប្រកបដោយសុខសន្តិភាព ចូលរួមអនុវត្តសកម្មភាពដើម្បីសម្រេចគោលបំណងរួម គឺបង្ការទប់ស្កាត់សំដៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់។

៣.បង្ហាញពីតួនាទីសំខាន់របស់សាសនា និងជំហរក្នុងការបន្តចូលរួមពីសំណាក់មេដឹកនាំ និងសាសនិកពីគ្រប់និកាយសាសនា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## I. **សមាសភាពយាងនិមន្ត និងអញ្ជើញចូលរួម**

១-សម្តេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការ និងជាព្រះអនុប្រធានលេខាធិការដ្ឋាន គណៈសង្ឃនាយកគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

២-សម្តេចព្រះមង្គលទេព្វាចារ្យ **វង្ស អានេតា** សម្តេចព្រះសង្ឃនាយករង គណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

៣-អ្នកឧកញ៉ា **សុះ កាំរី** ចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា

៤-លោកឧកញ៉ា **ឃ្មួ ម៉ាត់សា** មេដឹកនាំឥស្លាម ក្រុមកនអ៊ីម៉ាំសាន់
៥-ឯកឧត្តម ព្រឹទ្ធបូជាចារ្យ **លន់ សូភី** ព្រឹទ្ធបូជាចារ្យជាន់ខ្ពស់គ្រិស្តសាសនា
៦-ឯកឧត្តម **ញ៉ែម និវត្តន៍** អភិបាលព្រះសហគមន៍កាតូលិក
៧-សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា សមាជិក ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃ បណ្តាក្រសួងស្ថាប័នគ្រប់លំដាប់ថ្នាក់ ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាង នៃបណ្តាប្រទេសជាមិត្តប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តំណាងនិកាយសាសនា តំណាងសហគ្រិនស្ត្រី តំណាងសិល្បៈករកម្ពុជា និងយុវជន យុវនារី សរុបចំនួនប្រហែល **២.២៥០**អង្គ/នាក់។

## II. មតិស្វាគមន៍ និងសាវតារទិវាជាតិ ២០ សីហា

ជាកិច្ចចាប់ផ្តើម លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងនូវ អំណរព្រះគុណ និងអំណរគុណ និងសូមនមសការថ្វាយបង្គំ ស្វាគមន៍ចំពោះព្រះរាជវត្តមាន ព្រះវត្តមាន វត្តមាន សម្តេច ព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ អ្នកដឹកនាំសាសនាឥស្លាម និងសាសនាគ្រិស្ត គ្រប់និកាយ វត្តមានដ៏ឧត្តុង្គឧត្តម **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ថ្នាក់ដឹកនាំក្រសួងស្ថាប័ន អភិបាល អភិបាលរង រាជធានី ខេត្ត កងកម្លាំងសមត្ថកិច្ចគ្រប់ប្រភេទ លោក-លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ យុវជន យុវនារី សិស្សនុសិស្ស សមាជិក សមាជិកា នៃអង្គពិធី ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញចូលរួមក្នុងទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤ នៅថ្ងៃនេះ។ លោកជំទាវ ក៏បានទូលថ្វាយ ប្រគេន និងជម្រាបជូនអំពីសារៈសំខាន់នៃការរៀបចំទិវាជាតិអន្តរសាសនា៖

ទិវាជាតិ អន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ២០សីហា នេះ ត្រូវបានចាប់ផ្តើម ប្រារព្ធធ្វើឡើង លើកទី១ នៅឆ្នាំ២០១៧ ក្រោមការផ្តួចផ្តើមពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការការីតាសកម្ពុជា មេដឹកនាំសាសនាធំៗទាំងបី និងក្រសួងធម្មការ និងសាសនា ដោយឯកភាពគ្នា រៀបចំជាវេទិកាអន្តរសាសនា ប្រឆាំងអំពើជួញដូរមនុស្ស។ នៅឆ្នាំ២០១៩ កម្មវិធីបានទទួលការចូលរួមពីក្រុមគណៈប្រតិភូសាសនាពីបណ្តាប្រទេសចំនួន ១៥ក្រុម ក្នុងតំបន់មកចូលរួម និងសិក្សារៀនសូត្រពីភាពសុខដុមនីយកម្មសាសនានៅកម្ពុជា ដែលមានការមូលមតិគ្នាចូលរួមបង្ការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយឆន្ទៈខ្ពស់។ ឆ្នាំ ២០២០ និងឆ្នាំ២០២១ គឺជាដំណាក់កាលរាលដាលជំងឺកូវីដ-១៩ មិនមានការរៀបចំជួបជុំទ្រង់ទ្រាយធំទេ គឺបានត្រឹមការប្រកាសបើកកម្មវិធីនៅទូទាំងប្រទេស ដោយបំផុសឱ្យមានការទូងស្គរ គោះជួង គោះរគាំង កងរំពង គ្រប់អារាមសាសនា និងមានការផ្សព្វផ្សាយនូវបទយកការណ៍អមដោយរបាយការណ៍ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្លែងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបានចាក់ផ្សាយតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គមព្រមៗគ្នាក្នុងពេលតែមួយ។ ឆ្នាំ២០២២ បន្ទាប់ពី មានការថមថយការរាតត្បាតជំងឺកូវីដ-១៩ កម្មវិធីអន្តរសាសនា ត្រូវបានរៀបចំជាទ្រង់ទ្រាយធំឡើងវិញ ដោយមានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងប្រកាសយកថ្ងៃទី២០ ខែសីហា ជា «**ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស**» រៀងរាល់ឆ្នាំ។ នៅឆ្នាំ២០២៣ គឺជាពេលវេលាដ៏មមាញឹក ដែលត្រូវរៀបចំរាជរដ្ឋាភិបាល

នីតិកាលទី៧ ដូច្នេះ ការប្រារព្ធទិវានេះ ត្រូវបានធ្វើឡើងត្រឹមតែជាការប្រកាសព័ត៌មាន និងផ្សព្វផ្សាយបទយកការណ៍តែប៉ុណ្ណោះ។

លោកជំទាវបញ្ជាក់ថា បច្ចុប្បន្នពិភពលោក មានការវិវឌ្ឍន៍រីកចម្រើនយ៉ាងលឿនមហិមា នៃបច្ចេកវិទ្យា វិទ្យាសាស្ត្រព័ត៌មាន ដែលហៅថា ឌីជីថល ដែលបាន និងកំពុងជំរុញឱ្យមានការរីកចម្រើនគ្រប់វិស័យនៅទូទាំងពិភពលោក។ ទន្ទឹមនឹងនោះ ប្រព័ន្ធបច្ចេកវិទ្យានេះ ក៏បម្រើឱ្យការផលិតអាវុធទំនើបប្រល័យលោក កាន់តែមានប្រសិទ្ធភាព និងបម្រើឱ្យជនល្មើសអាចធ្វើសកម្មភាពឧក្រិដ្ឋកាន់តែងាយស្រួល និងរីករាលដាល កាន់តែឆាប់រហ័សហួសពីការស្មានផងដែរ មានន័យថា ភាពវៃឆ្លាតក្នុងចំណេះដឹងវិទ្យាសាស្ត្រតែម្យ៉ាង មិនអាចនាំមកនូវសេចក្តីសុខដល់មនុស្សជាតិ និងពិភពលោកបានទេ បើមនុស្សអ្នកបង្កើត និងប្រើប្រាស់វិទ្យាសាស្ត្រ គ្មានសីលធម៌ គ្មានគុណធម៌ មិនមានចេតនា បង្កើតឱ្យមានសេចក្តីសុខ។

ឆ្នាំ២០២៤នេះ ក្រុមការងារ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានការចូលរួមពីអន្តរក្រសួង មានជាអាទិ៍ ក្រសួងធម្មការ និងសាសនា ក្រសួងព័ត៌មាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងសាសនាទាំងបី អង្គការមិនមែនរដ្ឋាភិបាល សហគ្រិនស្ត្រី សមាគមសិល្បករកម្ពុជា ជាតំណាងវិស័យឯកជន បានមូលមតិគ្នាជ្រើសយកប្រធានបទ «**ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល**» សម្រាប់ទិវាជាតិអន្តរសាសនា ប្រចាំឆ្នាំ២០២៤ ដែលសមស្របទៅនឹងសភាពការណ៍ជាក់ស្តែង ដែលព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាពិភពលោកកំពុងប្រឈមយ៉ាងខ្លាំងទៅនឹងផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន។

### III. ព្រះថេរដីកាសម្តេចព្រះមហាអរិយវង្សបណ្ឌិត យ៉ន សេងយៀត

ក្នុងឱកាសនោះផងដែរ **សម្តេចព្រះមហាអរិយវង្សបណ្ឌិត យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងជាព្រះអនុប្រធានលេខាធិការដ្ឋានគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា មានព្រះថេរដីកាបញ្ជាក់ពីភាពសំខាន់នៃការចូលរួមចំណែកពីវិស័យសាសនាទាំងអស់ ក្នុងការអប់រំ ណែនាំដល់បរិស័ទឱ្យយល់ដឹង និងចូលរួមបង្ការទប់ស្កាត់ពីអំពើជួញដូរមនុស្សនេះ។ **សម្តេចព្រះមហាអរិយវង្សបណ្ឌិត** បានអំពាវនាវដល់មេដឹកនាំសាសនា និងសាសនិកទាំងអស់នៅកម្ពុជាថា អ្នកដឹកនាំសាសនាត្រូវចូលរួមអប់រំបរិស័ទរបស់ខ្លួនឱ្យយល់ដឹងពីអំពើជួញដូរមនុស្ស និងផលប៉ះពាល់ដែលកើតមាន ដោយគប្បីអប់រំមនុស្សឱ្យចេះរស់នៅធ្វើល្អឱ្យបានច្រើននៅលើភពផែនដីនេះ ជាជាងបង្រៀនមនុស្សឱ្យឡើងឋានសួគ៌។ ការជួញដូរមនុស្សអាចកើតមានលើបុគ្គលគ្រប់រូប មិនប្រកាន់អ្នកមាន ឬគ្មានជំនឿសាសនានោះឡើយ យើងត្រូវចូលរួមជួយទាំងអស់គ្នា ព្រោះបុគ្គលណាក៏អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរ ដូច្នេះយើងមិនត្រូវស្ងប់ស្ងៀម មិនត្រូវបិទភ្នែកនៅពេលដឹងថាមានឧក្រិដ្ឋកម្មជួញមនុស្សកើតឡើងនោះទេ គឺត្រូវចូលរួមសហការជាមួយរាជរដ្ឋាភិបាល និងរាយការណ៍ដល់អាជ្ញាធរពាក់ព័ន្ធ ប្រសិនបើយើងបានជួបប្រទះ ឬក៏បានដឹង បានឃើញ ថាមានអំពើជួញដូរមនុស្ស។ វិស័យសាសនាត្រូវដើរតួជាគំរូ និងចូលរួមយ៉ាងសកម្មក្នុងការប្រៀនប្រដៅ ផ្តល់ឱវាទ ណែនាំដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តួនាទីរបស់បុព្វជិតសាសនា មានសារៈសំខាន់ខ្លាំងណាស់ក្នុងការចូលរួមជួយគាំទ្រ ផ្តល់ភាពសង្គ្រោះដល់ជនរងគ្រោះតាមរយៈសាសនារបស់ខ្លួន ប្រកបដោយមេត្តា និងគ្មានការរើសអើង។

ក្រោយពីបានបញ្ចប់ ព្រះថេរដីការ **សម្តេចព្រះមហាអរិយវង្សបណ្ឌិត** រួចមក ក៏មានកិច្ចសូត្រព្រះធម៌ ដើម្បីបួងសួង អធិដ្ឋានសុំសេចក្តីសុខ តាមសាសនានីមួយៗ ជាបន្តបន្ទាប់។

III. **មតិវាយតម្លៃ និងអនុសាសន៍**

ក្នុងឱកាសដ៏ថ្លៃថ្លានេះ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងកោតសរសើរដល់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ បានបន្តប្រារព្ធទិវាជាតិអន្តរសាសនានេះយ៉ាងខ្ជាប់ខ្ជួន ដើម្បីបន្តជំរុញឱ្យមានការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ពីវិស័យសាសនា នៅក្នុងការបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល។ **ឯកឧត្តមអភិសន្តិបណ្ឌិត** បានបញ្ជាក់បន្ថែមថា ការរីកចម្រើនដ៏ឆាប់រហ័សនៃបច្ចេកវិទ្យា វិទ្យាសាស្ត្រ គួបផ្សំនឹងសមត្ថភាព ជំនាញរបស់អ្នកប្រើប្រាស់ ដែលកើនឡើងយ៉ាងខ្លាំងផងដែរ បានធ្វើឱ្យបទល្មើសកាន់តែស្មុគស្មាញ និងបង្កផលវិបាកជាអវិជ្ជមានសក្នុងសង្គម ក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ មិនបានព្រងើយកន្តើយឡើយ ហើយតែងតែអំពាវនាវឱ្យមានកិច្ចសហការកាន់តែរឹងមាំពីបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយទាំងក្នុងតំបន់ និងជាអន្តរជាតិ ឱ្យរួមគ្នាដោះស្រាយ។ រាជរដ្ឋាភិបាល ក៏បានដាក់ចេញ និងបន្តអនុវត្ត ផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដោយប្រុងប្រយ័ត្ន និងដោយគ្មានការធ្វេសប្រហែស។ គោលការណ៍សំខាន់បួននៃផែនការប្រតិបត្តិនេះ មាន៖ (១)សង្គ្រោះជនរងគ្រោះឱ្យទាន់ពេលវេលា (២)ស៊ើបអង្កេតរកជនប្រព្រឹត្តបទល្មើស និងបក្សពួក ស្រាវជ្រាវរកមេក្លោងដើម្បីផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង (៣)ត្រួតពិនិត្យ ប្រមូលភស្តុតាងដើម្បីបិទអាជីវកម្មខុសច្បាប់ពាក់ព័ន្ធ និង(៤)ពន្លាតការស៊ើបអង្កេតរកសកម្មភាពបទល្មើសសម្អាតប្រាក់របស់ជនល្មើស។

ជាទីបញ្ចប់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមប្រមុខរាជរដ្ឋាភិបាល បានផ្តល់នូវអនុសាសន៍សម្រាប់អនុវត្តបន្តក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចតទៅ៖ (១)បន្តការអប់រំសីលធម៌តាមគន្លងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរស់នៅប្រកបដោយសីលធម៌ និងគុណធម៌ សម្រាប់ឱ្យមនុស្សភ្ញាក់រលឹក និងទទួលយកការយល់ដឹងអំពីបទល្មើសជួញដូរមនុស្ស និងផលប៉ះពាល់ដើម្បីបង្ការទប់ស្កាត់ ធ្វើឱ្យមានសេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្ត និងមិនប្រព្រឹត្តទង្វើទុច្ចរឹត ឬបទល្មើសផ្សេងៗដែលនាំទុក្ខដល់ខ្លួន (២)អំពាវនាវឱ្យមានកិច្ចសហការកាន់តែប្រសើរឡើងរវាង ក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ជាពិសេស មេដឹកនាំសាសនាធំៗទាំងបី ក្រោមការសម្របសម្រួលពី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលដឹកនាំដោយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ដើម្បីរៀបចំផែនការសកម្មភាពបន្តឱ្យបានជាក់លាក់ ងាយស្រួលដល់ការធ្វើសកម្មភាពព្រមៗគ្នា និងមានទិន្នន័យជាលទ្ធផលសម្រាប់ការរៀបចំទិវាជាតិអន្តរសាសនាលើកក្រោយទៀត និង(៣)សូមអំពាវនាវដល់ អាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជួយបង្កលក្ខណៈងាយស្រួលដល់ការធ្វើសកម្មភាព អប់រំតាមបែបសាសនា ក្នុងគោលដៅបង្កើតឱ្យមានប្រព័ន្ធសុវត្ថិភាពនៅតាមបណ្តា ភូមិ ឃុំ សង្កាត់ទូទាំងប្រទេស ដែលនឹងជួយពង្រឹងដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គម។

ទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៤ ក្រោមប្រធានបទ «ការអប់រំសីលធម៌តាមវិស័យសាសនា បង្ការទប់ស្កាត់អំពើជួញដូរមនុស្សសម័យឌីជីថល» បានបញ្ចប់នៅវេលាម៉ោង ប្រាំបួន និងសែសិបប្រាំនាទីព្រឹក ថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃសុក្រ ៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤
អ្នកធ្វើកំណត់ហេតុ

វរសេនីយ៍ឯក.អ៊ិច ចាន់ធា

បានពិនិត្យ និងគោរពជូន
លោកជំទាវ អគ្គលេខាធិការ មេត្តាជ្រាបជារបាយការណ៍។
ថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤
**អគ្គលេខាធិការរងទទួលបន្ទុក**

ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ

បានពិនិត្យ និងគោរពជូន
លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
ថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណា សំខាន់

បានឃើញ
27/08/24

ដួ ប៊ុនអេង